# សវនាការពន្យារពេលដោយសារសុខភាពរបស់សាក្សី

***ដោយ គ្រីសស៊ីន អ៊ីវេន***

***ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១១***

*កែប្រែសម្រួលដោយ ជា ផល្លា*

ថ្ងៃនេះអង្គជំនុំជម្រះបានពន្យាពេលសវនាការលើភ័ស្តុតាងក្នុងសំណុំរឿង០០២ ដោយសារតែបញ្ហាសុខភាពសាក្សីរបស់ព្រះរាជអាជ្ញា ឡុង នរិន្ទ។ ក្រោយពីចៅក្រមបានជម្រាបទៅគ្រប់ភាគី និងសាធារណជនថា សវនាការថ្ងៃនេះអាចយឺតមួយម៉ោង ដោយសារមន្ត្រីរបស់សាលាក្តីខ្មែរក្រហមព្យាយាមពិនិត្យមើលពីស្ថានភាពរបស់សាក្សី ចៅក្រមក៏បានប្រកាសថា សវនាការនិងចាប់ផ្តើមក្រោយម៉ោងប្រាំបួនព្រឹក។ ចៅក្រម និល ណុន បានជម្រាបទៅសាក្សីទាំងអស់ថា ដោយសារតែស្ថានភាពសុខភាពរបស់ ឡុង នរិន្ទ មិនសូវល្អ តុលាការនឹងមិនអាចដំណើការបានទេនៅថ្ងៃនេះ។ ក្រោយមកចៅក្រម និល ណុន បានបិទសវនាការសម្រាប់ថ្ងៃចុងសប្តាហ៍នេះ បង្កឲ្យមានការរអ៊ូរទាំពីសំណាក់អ្នកចូលរួមនៅខាងក្រៅតុលាការ។ អ្នកចូលរួមក្នុងសវនាការជាច្រើនឆ្ងល់ថា ហេតុអ្វីក៏មិនបន្តសក្ខីកម្មរបស់ នួន ជា ព្រោះព្រឹកនេះ នួន ជា ក៏មានវត្តមាននៅក្នុងបន្ទប់សវនាការដែរ។

ដោយសារតែថ្ងៃចន្ទសប្តាហ៍ក្រោយជាថ្ងៃឈប់សម្រាក់នៃទិវាសិទ្ធមនុស្សអន្តរជាតិ ដំណើរការសវនាការក្នុងសំណុំរឿង០០២នឹងពន្យាពេលរហូតដល់ថ្ងៃអង្គារ ទី១៣ ខែធ្នូ ឆ្នាំ២០១១វិញ។ សាក្សី ឡុង នរិន្ទ ត្រូវបានគ្រោងថានិងបន្តធ្វើសក្ខីកម្មនៅថ្ងៃអង្គារនោះ ហើយថ្ងៃនោះដែរបើសិនជា ឡុង នរិន្ទ មានសុខភាពមិនល្អទៀត នួន ជា និងត្រៀមចូលធ្វើសក្ខីកម្មនៅថ្ងៃនោះ។

**-ចប់-**